# ការអភិវឌ្ឍន៍នៃកំណាព្យខ្មែរ

ណុល ដារ៉ា

Cambodian poetry

NOL Dara

ទិសដៅថ្មីរបស់យើងក្នុងការអភិវឌ្ឍន៍កំណាព្យ គឺធ្វើយ៉ាងណាអោយកំណាព្យរបស់យើងទាន់សម័យទំនើប និងអាចទាន់កំរិតអន្តរជាតិ។ ការពិត កាលណាយើងនិយាយពីការអភិវឌ្ឍន៍កំណាព្យ គឺយើងនិយាយពីការអភិវឌ្ឍន៍ចំណេះដឹងរបស់កវី អ្នកនិពន្ធ។ ដើម្បីសម្រេចបំណងនេះ យើងមើលទៅលើកំណាព្យ និងអ្នកនិពន្ធដែលយើងមានមកហើយ និងចំណុចខ្វះខាតរបស់កំណាព្យយើង។

## ១ កវីនិងកំណាព្យខ្មែរ

ខ្មែរយើងមានក្បួនតែងកាព្យនិងរបៀបសូត្រកំណាព្យដ៏សម្បូរបែប។ បើតាមសៀវភៅសិល្បៈតែងកំណាព្យ របស់លោកពេជ្រ ទុំក្រវិល មានកំណាព្យទាំងអស់៥៣បទ ប៉ុន្តែគេរកឃើញរបៀបសរសេរបានត្រឹម ៥០ប៉ុណ្ណោះ។ ផ្អែកតាមរយៈភាពសម្បូរបែបនេះ បញ្ជាក់អោយឃើញថា បុព្វបុរសខ្មែរយើងនិយមកំណាព្យណាស់។ អ្នកសិក្សាបានអោយដឹងថាកំណាព្យមាននៅក្នុងស្រុកខ្មែរយើងតាំងពីសម័យហ្វូណន ដែលកំណាព្យពេលនោះមាននៅក្នុងវង់ភ្លេងអារក្ស ភ្លេងប្រពៃណី និងក្នុងពិធីសាសនាដែលគេសូត្រថ្វាយអាទិទេព។ ជាភ័ព្វសំណាង យើងបានស្គាល់ឈ្មោះកវី អ្នកនិពន្ធល្បីៗរបស់យើងតាមរយៈការប្រមូលចងក្រងជាឯកសាររបស់លោកលី ធាមតេង។

កវីដែលលេចធ្លោជាងគេតាំងពីសម័យសង្គមរាស្ត្រនិយមមានលោកកេង វ៉ាន់សាក់ សម័យសាធារណរដ្ឋមានលោកគយ សារុន។ ក្នុងសម័យសព្វថ្ងៃនេះ មានកវីជាច្រើនរូបដែលបានទទួលរង្វាន់ផ្សេងៗគ្នាមួយចំនួន និងកវីជើងចាស់ដែលមានឈ្មោះល្បីដូចជាលោកគង្គ ប៊ុនឈឿន ជាដើម។ ក្នុងសម័យសង្គមរាស្ត្រនិយមនិងសម័យសាធារណរដ្ឋ ហាក់ដូចជាមានបដិវត្តន៍ផ្នែកកំណាព្យមួយបានកើតឡើង ព្រោះរបៀបសរសេរនិងរបៀបគិតខុសពីសម័យមុនៗដែលភាគច្រើនគឺការប្រៀនប្រដៅ។ គេសរសេរពីហេតុការណ៍រឿងរ៉ាវនិយាយដោយខ្លួនឯង គេមិនបានប្រៀនប្រដៅទៀតទេ គឺគេទុកអោយអ្នកអានវិនិច្ឆ័យដោយខ្លួនគាត់ផ្ទាល់។ នៅក្នុងសម័យសាធារណរដ្ឋប្រជាមានិត្យកម្ពុជា និងសម័យរដ្ឋកម្ពុជា ការសរសេរកំណាព្យបានវិលទៅចូលគន្លងចាស់វិញដោយភាគច្រើនសំរាំងតែទៅលើការទូន្មានប្រៀនប្រដៅ។ មកដល់សម័យព្រះរាជាណាចក្រកម្ពុជាយើងទីពីរនេះ មាននិន្នាការពីរបានកើតឡើងគឺអភិរក្សនិយម និងទំនើបនិយម។ ខាងអភិរក្សនិយមយក

ចិត្តទុកដាក់ច្រើនលើក្បួនតែងកាព្យ និងធ្វើយ៉ាងណាអោយជើងកាព្យល្អ ចាប់ចុងជួនផ្ទួនរណ្ដំ សរសេរបែបទូន្មានប្រៀនប្រដៅ ឬបង្ហាញពីអ្វីដែលគេស្រលាញ់ចូលចិត្ត ឬបញ្ចេញនូវកំហឹង និងការឈឺចាប់។ ខាងទំនើបនិយមជ្រើសរើសយកក្បួនតែងកាព្យងាយៗដូចជាបទកាកគតិ និងបទពាក្យ៧ជាដើម ហើយគេគិតយ៉ាងណាអោយកំណាព្យរបស់គេមានជំរៅបែបទស្សនវិជ្ជា ការប្រៀបធៀប និងព្រឹត្តិការណ៍ជាក់ស្ដែងសំរាប់អ្នកអានគិតពិចារណា បានជាមេរៀនឬដកស្រង់បទពិសោធន៍សំរាប់ជីវិត។

## ២ គ្រឹះនៃការអភិវឌ្ឍន៍

ចំណុចខ្វះខាតដើម្បីធ្វើការអភិវឌ្ឍន៍ដែលមើលឃើញជាគោលគឺ ÷

-កវីចូលចិត្តប្រៀនប្រដៅអ្នកអានរបស់ខ្លួន ដែលអាចចាត់ថាជាការហួសសម័យ។

-កវីផ្ដល់គំនិតនិងប្រាប់ផ្លូវអោយអ្នកអានតែម្ដង។

-កវីភ័យនឹងការចាប់ចុងជួនខ្លាចក្រែងពុំបានល្អ។

-ចំណេះដឹងរបស់កវីមានកំរិត។

-កវីខ្លាចស្នាដៃរបស់ខ្លួនខ្លីពេក ខំព្យាយាមបន្លាយអោយវែង។

-កវីមិនទាន់មានបច្ចេកទេសក្នុងការបញ្ចប់កំណាព្យរបស់ខ្លួន ក្នុងការបើកទ្វារចំហអោយអ្នកអានគិតពិចារណាដោយខ្លួនឯង។

ខ្ញុំមិនដឹងថាលោក លោកស្រីយល់ស្របយោបល់តាមទេ លើចំនុចខ្វះខាតទាំងអស់ខាងលើនេះ តែនេះគ្រាន់តែជាគោលការណ៍សំរាប់លោក លោកស្រីយកទៅពិភាក្សាក្នុងក្រុមប៉ុណ្ណោះ។ ថ្ងៃមុនខ្ញុំបានប្រទះឃើញអត្ថបទមួយឆ្លើយតបទៅនឹងយោបល់របស់យុវជនដែលនិយាយថា គេមិនចូលចិត្តកំណាព្យទេ តែគេចូលចិត្តចំរៀង។ លោកកែវ កវី បានសរសេរអត្ថបទសាកល្បងមួយផ្សាយក្នុងសារព័ត៌មាន អ្នកស្រុកខ្មែរ អំពីអ្នកអាន និងអក្សរសាស្ត្រខ្មែរទំនើប។ ខ្ញុំសូមលើកយកអត្ថបទនោះទាំងស្រុងមកបង្ហាញជូនដូចតទៅ ÷

«ថ្មីៗនេះ អ្នកអានក្មេងៗជាច្រើនបានបញ្ចេញមតិតាមសារព័ត៌មានថា គេមិនចូលចិត្តកំណាព្យទេគេចូលចិត្តតែចំរៀង។ ចំពោះខ្ញុំ ខ្ញុំយល់ថាក្មេងទាំងអស់នេះចូលចិត្តកំណាព្យ ព្រោះក្នុងចំរៀងមានកំណាព្យនៅក្នុងនោះ។ អ្វីដែលខ្ញុំយល់ថា ក្មេងពុំសូវចូលចិត្តក្នុងសម័យនេះ គឺការប្រៀនប្រដៅត្រង់ៗ ដែលមានក្នុងកំណាព្យបុរាណដូចជាថា អ្នកកុំធ្វើនេះ អ្នកកុំធ្វើនោះ ឬអ្នកគួរធ្វើដូច្នេះ ឬគួរធ្វើដូច្នោះជាដើម ព្រោះក្មេងសម័យនេះ គេបានទទួលព័ត៌មានច្រើនជាងសម័យមុន ពីកាសែត

ពីវិទ្យុ ពីទូរទស្សន៍ និងពីរឿងរ៉ាវជាច្រើនក្នុងភាពយន្ត។ លំនាំចិត្តរបស់ពួកគេ គេចង់ធ្វើការវិនិច្ឆ័យផ្ទាល់ខ្លួន ដោយគ្រាន់តែយកព័ត៌មានទាំងនោះមកប្រើប្រាស់ជាគ្រឹះ។ ការដែលក្មេងៗសម័យនេះចូលចិត្តចំរៀង ព្រោះក្នុងចំរៀងនិយាយរៀបរាប់តែពីរឿងរ៉ាវ និងអារម្មណ៍ប៉ុណ្ណោះ ហើយចំរៀងភាគច្រើនមួយចំនួនមិនទាំងប្រាប់រឿងរ៉ាវផង និយាយតែពីអារម្មណ៍។ ទាំងនេះជាអាកប្បកិរិយាទំនើបមួយដែលកវីសម័យថ្មីទទួលស្គាល់ថាជាការវិវត្តន៍នៃពេលវេលា ជាទំនោរនៃពេលវេលាដែលសោកនាដកម្មក្នុងជីវិត និងសេចក្ដីស្នេហាមានទំងន់ស្រាលជាងមុន គេមានម្ហូបអាហារបរិភោគគ្រប់គ្រាន់ជាងមុន គេមានសំភារៈប្រើប្រាស់ច្រើនជាងមុន សេចក្ដីភ្លើតភ្លើនរបស់គេក្នុងសេចក្ដីស្នេហាតំរង់ទិសទៅរកការទាក់ទងខាងផ្លូវភេទជាជាងមនោសញ្ចេតនា នេះគឺជាការជាក់ស្ដែងដែលមានសំដែងក្នុងចំរៀងខារ៉ាអូខេ ឬក៏ការឆ្លើយឆ្លងតាមទូរស័ព្ទជាមួយវិទ្យុក្នុងនាទីសំណូមពរបទចំរៀងជាដើម។ ក្នុងជំរៅផ្លូវប្រាជ្ញាស្មារតី យុវជនសម័យថ្មី សូម្បីតែនិស្សិតនិងសិស្សមិនសូវបានផ្ដល់អោយឃើញនូវតំលៃផ្នែកបញ្ញវ័ន្តដោយជ្រាលជ្រៅនៅឡើយទេ។

កវីទំនើបដែលជាអ្នកទំនើបនិយមមួយចំនួនបានចាប់អារម្មណ៍ និងទទួលស្គាល់តថភាពនៃសង្គមនេះ ប៉ុន្តែអ្វីដែលជាឧបសគ្គក្នុងការឆ្លងកាត់ពេលវេលានេះ គឺការទើសទាល់ក្នុងការផ្ដល់វិភាគទានរបស់ខ្លួនដល់សង្គម ដែលកវីទាំងអស់ត្រូវបំពេញក្នុងបេសកកម្មរបស់ខ្លួន ដែលមិនអាចកំរិតត្រឹមតែការកំសាន្តប៉ុណ្ណោះទេ។ ការដុះដាលរបស់សង្គមជាតិត្រូវការពង្រឹងនូវភាពបញ្ញវ័ន្តរបស់យុវជនសម័យថ្មីអោយមានជំហររឹងប៉ឹងខាងផ្លូវប្រាជ្ញាស្មារតី និងសេចក្ដីថ្លៃថ្នូរ។ ដូច្នេះអ្វីដែលកវីទំនើបត្រូវធ្វើក្នុងពេលនេះ គឺការអត់ធ្មត់ក្នុងការផ្ដល់ពេលវេលា និងរចនាកវីនិពន្ធរបស់ខ្លួនអោយមានលំនាំប្រហាក់ប្រហែលនឹងបទចំរៀង បើមិនដូច្នោះទេអក្សរសាស្ត្រទំនើបក៏មិនអាចឈានទៅរកការចំរើនជឿនលឿនទាន់សម័យបានដែរ»។

អត្ថបទសាកល្បងរបស់លោកកែវ កវីដែលខ្ញុំបានលើកមកបង្ហាញខាងលើនេះ ជាគំនិតមួយគ្រាន់ឱ្យយើងយកជាការពិចារណា ក្នុងការនាំយកកំណាព្យយើងទៅរកភាពទំនើបទាន់កំរិតអន្តរជាតិ៕